00304196

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / 04 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

E1/8

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

**<u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធី-ករណី “ឌុច”</u>**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

ថ្ងៃទី ០៦ ខែមេសា ឆ្នាំ ២០០៩

សវនាការលើអង្គសេចក្តី-ថ្ងៃទី ៤

**សាធារណៈ**

រៀបចំដោយ: លឹម ស៊ុយហុង និង ណាតាសា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 04 / 2009
ម៉ោង (Time/Heure): 14:02
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

| |
|---|
| <u>កំណត់ហេតុអ្នកចូលរួម</u> |
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖លោក លឹម ស៊ុយហុង,លោក ម៉ាតេអូ គ្រីប៉ា,លោកស្រី សែ កុលវុឌ្ឍី,កញ្ញា ណាតាសា, លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោកស្រី ជាលាង, លោក រ៉ូបឺត ប៉ុទី, លោក សេង ប៊ុនឃាង, លោក ពេជ្យ សម្បត្តិ, លោក អាឡិច សាន់ដឺបាត, លោក ប៉ាក ចន្ទលីណូ, លោក បូយ៉េន លីសាក |
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក ការ សាវុត្ថ, លោក ហ្វ្រង់ស័រ រូស, លោកស្រី ហេឡិន អ៊ុយណាក, លោក ចាន់ រ៉ាវុធ, លោកស្រី ម៉ារីប៉ូល កានីស្សា, កញ្ញា ហ្សង់ម៉ារី ត្រង់ទូល, កញ្ញា វីជីនី ឈេបផេន តៀ, កញ្ញា លុចសីល ណាតៀ |

| |
|---|
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ហុង គីមសួន, លោក គង់ ពិសី, លោក យ៉ុង ផានិត , កញ្ញា ស៊ិលខេ ស្ទូហ្សិនស្គី , កញ្ញា ម៉ុច សុវណ្ណារី, លោក ហ្វីលីព កាណូន, កញ្ញា ទី ស្រីនណា, លោក អាឡាំង វើនើ |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក សាន់ រ៉ាដា |
| អ្នកផ្សេងទៀត៖ លោក ស៊ុត ប៊ីវាធើ, កញ្ញា ជូលី ម៉ាស, លោក ព្យែរ ហ្គាស្សូត, កញ្ញា ម៉ារីវន មូសសូនដា ម៉ានីញាក់គី |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០០៩ ព្រឹក | ចាប់ផ្តើមម៉ោង៖ ៩.១០ | បញ្ចប់ម៉ោង៖ ១៦.២០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖១០.៥៥ |
| សម្រាក អាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖១២.០០ | បញ្ចប់ម៉ោង៖១.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖២.៤០ | បញ្ចប់ម៉ោង៖៣.០០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ម៉ោង ៥០ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| អង្គជំនុំជម្រះសាលាដំបូងឆ្លើយបំភ្លឺលើសំណើរបស់ភាគីដែលបានលើក | អង្គជំនុំជម្រះសាលាដំបូង | ៩.១២ | ៩.២០ |
| ការទទួលស្គាល់មេធាវីបរទេស | អង្គជំនុំជម្រះសាលាដំបូង | ៩.២៣ | ៩.២៤ |
| ការសួរសំណួរដល់ជនជាប់ចោទទាក់ទងនឹងអង្គហេតុ ម១៣ | អង្គជំនុំជម្រះសាលាដំបូង | ៩.៣០ | |
| ការបដិសេធលើការប្រើប្រាស់ឯកសារ D9 | មេធាវីការពារក្តី | ១៤.០៥ | ១៦.១៥ |

| | | | |
|---|---|---|---|
| ស្នើសុំអោយមានសេចក្តីសម្រេចលើការប្រើប្រាស់ឯកសារ D9 | សហព្រះរាជអាជ្ញា | | |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការទទួលស្គាល់មេធាវីបរទេសដោយអនុលោមតាមវិធាន ២៣ (៧)(ង)(ក)**

លោកមេធាវី Philippe Canonne ត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះសាលាដំបូងបន្ទាប់ពីការណែនាំដោយមេធាវីជាតិតំណាងអោយ ដើមបណ្តឹងរដ្ឋប្បវេណី។

**ការសួរសំណួរដល់ជនជាប់ចោទលើអង្គហេតុ ម ១៣៖**

មុននឹងចាប់ផ្តើមសួរសំណួរទៅជនជាប់ចោទ អំពីអង្គហេតុពាក់ព័ន្ធនឹង ម.១៣ អង្គជំនុំជម្រះសូមជម្រាបថា:

អង្គហេតុដែលបានប្រព្រឹត្តនៅ ម. ១៣ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវមិនមែនជាផ្នែកនៃអង្គហេតុដែលមាននៅក្នុងដីកាបញ្ជូនរឿងមកជំនុំជម្រះទេ។ ប៉ុន្តែ ដើម្បីបានយល់ឲ្យកាន់តែច្បាស់នូវបរិបទរបស់ ស. ២១ រួមមានអង្គការចាត់តាំងរចនាសម្ព័ន្ធ ប្រតិបត្តិការរបស់ ស ២១ និងហេតុផលនានា និងបុគ្គលភាពរបស់ជនជាប់ចោទផងនោះ ដូច្នេះនៅពេលសវនាការនេះវាពិតជាមានការពាក់ព័ន្ធ និងចាំបាច់ត្រូវត្រួតពិនិត្យលើបញ្ហាទាំងនេះដែលជនជាប់ចោទខ្លួនឯងផ្ទាល់បានរៀបរាប់ទាំងនៅដំណាក់កាលស៊ើបសួរ និងការឆ្លើយតបលើកដំបូងទៅនឹងការចោទប្រកាន់។

អង្គជំនុំជម្រះប្រើឯកសារនានាដែលមាននៅក្នុងសំណុំរឿងសម្រាប់សាកសួរគឺ:

- ចម្លើយរបស់ ហាម អ៊ិន (ឯកសារ DC CAM ឧបសម្ព័ន្ធ ៤, D59)
- ចម្លើយរបស់ អ៊ិន វន (ឯកសារ DC CAM ឧបសម្ព័ន្ធ ១២, D59)
- "របាយការណ៍ ៦៤/៧៥/០៨, បញ្ហាចំណុច ១៨" ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ឯកសារលេខ 19.25
- អត្ថបទដកស្រង់ចេញពី DC CAM ទស្សនាវដី ស្វែងរកការពិត បោះពុម្ពពិសេសនៅខែ កក្កដា ឆ្នាំ ២០០៣ " ប្រព័ន្ធសន្តិសុខ របស់ តំបន់ពិសេស ម. ១៣" ERN 00080395-00080457
- ចម្លើយរបស់ជនជាប់ចោទ ជាមួយ តំណាង UNHCR លោក Christophe Peschoux, ឯកសារ D9 ។

**ការប្រើប្រាស់ឯកសារ D9៖**

មេធាវីការពារជនជាប់ចោទបានបដិសេធទៅនឹងការប្រើប្រាស់ឯកសារនេះដោយមូលហេតុថាជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ត្រូវបានសម្ភាសន៍ដោយ UNHCR កាលពីថ្ងៃទី ០៤-០៦ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលការសម្ភាសន៍នេះមិនត្រូវបានធ្វើឡើងតាមផ្លូវតុលាការដែលជនជាប់ចោទមិនត្រូវបានប្រាប់សិទ្ធិក្នុងការរក្សាភាពស្ងាត់ស្ងៀមមិនឆ្លើយ។

សហព្រះរាជអាជ្ញាបានលើកឡើងថាឯកសារនេះត្រូវបានដាក់ចូលក្នុងសំណុំរឿងរួចហើយ ហើយស្នើសុំអោយមានសេចក្តីសម្រេចពីអង្គជំនុំជម្រះថាតើឯកសារនេះគួរត្រូវបានយកមកប្រើដែរឬទេ។

អង្គជំនុំជម្រះសាលាដំបូងបានស្នើអោយភាគីដាក់សេចក្តីសន្និដ្ឋានរបស់ពួកគេ (កំណត់ត្រឹម ២ ទំព័រសម្រាប់ភាសាអង់គ្លេស និងភាសាបារាំង ហើយត្រឹម ៤ទំព័រសម្រាប់ភាសាខ្មែរ) កំណត់ត្រឹមថ្ងៃទី ០៨ ខែមេសា ឆ្នាំ ២០០៩ ហើយអង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចក្នុងពេលសមស្របមួយ។

ជនជាប់ចោទត្រូវបានសួរសំណួរដោយអង្គជំនុំជម្រះសាលដំបូងទៅលើ:

- បរិបទនយោបាយនិងប្រវត្តិសាស្ត្រ នៅក្នុងអំឡុងពេលនោះ។
- ការឃុំខ្លួនជនជាប់ចោទក្នុងឆ្នាំ ១៩៦៩-១៩៧០ និង បច្ច័យនានាអំពីការឃុំខ្លួននេះ។
- តួនាទីរបស់ជនជាប់ចោទ នៅពេលបង្កើត ម. ១៣។
- ការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទក្នុងបក្សកុំម្មុយនីស្តកម្ពុជា។

មេធាវីការពារជនជាប់ចោទបានស្នើសុំអោយអ្នកបកប្រែប្រាប់ប្រសិនបើគេស្តាប់មិនទាន់ ឬស្តាប់មិនបាន។ ហើយស្នើថានៅពេលជនជាប់ចោទនិយាយពីឈ្មោះទីកន្លែងណាមួយ ឬឈ្មោះអ្នកណាម្នាក់សុំអោយអោយឈ្មោះទាំងនោះមានឃើញលើអេក្រង់។ អង្គជំនុំជម្រះសម្រេចទទួលយកសំណើរបស់មេធាវីការពារក្តី ហើយបានស្នើអោយជនជាប់ចោទនិយាយអោយបានយឺតជាងមុនដើម្បីងាយស្រួលដល់ការបកប្រែ។ អង្គជំនុំជម្រះក៏បានបញ្ជាក់ដែរថាអង្គជំនុំជម្រះនឹងខិតខំសម្របសម្រួលជាមួយផ្នែក ICT ដើម្បីអោយឈ្មោះទីកន្លែង ឬឈ្មោះមនុស្សមានចេញលើអេក្រង់ពេលមានការលើកពីឈ្មោះណាមួយ។

អង្គជំនុំជម្រះសាលាដំបូងបានអាននូវកំណត់ហេតុសួរចម្លើយរបស់ ឌុច ដោយសហចៅក្រមស៊ើបអង្កេត កាលពីថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៧ (ឯកសារ D21, ទំព័រទី ១១ ក្នុង ឯកសារជាភាសាអង់គ្លេស) (ទំព័រ ១២ ក្នុងឯកសារជាភាសាបារាំង)។ មានការបញ្ជាក់ថាក្នុងឯកសារដែលសរសេរ ម១៣ K គឺចង់សំដៅដល់ឯកសារ ម១៣ A។

| កំណត់ហេតុនៃដំណើការនីតិវិធីផ្អែកតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង | | |
|---|---|---|
| លេខឯកសារយោង | ឈ្មោះ/សេចក្តីអធិប្បាយ | ផ្សេងៗ |
| E3/1 | ចម្លើយរបស់ជនជាប់ចោទ ជាមួយ តំណាង UNHCR | ឯកសារ D9 |
| E3/2 | កំណត់ហេតុនៃការសួរចម្លើយ ឌុច ដោយសហចៅក្រមស៊ើបថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០៧ | ឯកសារ D21 |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

១. សំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ២ ដែលស្នើសុំសិទ្ធិថ្លែងតបទៅនឹងការថ្លែងរបស់ជនជាប់ចោទដែលឆ្លើយតបទៅនឹងការធ្វើសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាត្រូវបានបដិសេធ។

២. ក/ សំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការដាក់សេចក្តីសន្និដ្ឋានតបទៅនឹងសំណើរបស់មេធាវីការពារក្តីដែលបានស្នើសុំអោយមានការដោះលែងជនជាប់ចោទអោយនៅក្រៅឃុំក្នុងអំឡុងពេលជំនុំជម្រះ ក៏ដូចជាឯកសារដែលបានដាក់ដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម ៣ កាលពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០០៩ (ឯកសារ E39) ដែលបញ្ជាក់ពីសេចក្តីសន្និដ្ឋានរបស់ខ្លួនលើការដោះលែងជនជាប់ចោទត្រូវបានបដិសេធចោល។

២. ខ/ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្នើអោយធ្វើសេចក្តីសន្និដ្ឋានតបទៅនឹងការស្នើរបស់មេធាវីការពារជនជាប់ចោទដែលបានលើកថា ១/ រយៈពេលនៃការឃុំខ្លួនជនជាប់ចោទនៅតុលាការយោធាត្រូវរាប់បញ្ចូលប្រសិនមានការផ្តន្ទាទោសហើយថា ២/ រយៈពេលនេះត្រូវកាត់ចេញពីរយៈពេលនៃការផ្តន្ទាទោសប្រសិនបើជនជាប់ចោទត្រូវបានផ្តន្ទាទោសព្រោះការឃុំខ្លួនកន្លងមកគឺជាការរំលោភលើសិទ្ធិរបស់ជនជាប់ចោទ។ ការឆ្លើយតបត្រូវធ្វើក្នុងរយៈពេល៥ថ្ងៃគិតចាប់ពីថ្ងៃនេះ។

៣. បង្គាប់ឲ្យភាគីទាំងអស់ធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខអក្សរចំពោះការយល់ឃើញរបស់ភាគីទាក់ទងនឹងឯកសារ D9 ស្តីពីបទសម្ភាសន៍ ឌុច ជាមួយតំណាង UNHCR (ឧបសម្ព័ន្ធ គ លេខ ២០.១៩ កាលពីថ្ងៃទី ៤-៦ ឧសភា ឆ្នាំ ១៩៩៩) ដែលយោងទៅលើជើងទំព័រលេខ ៧១០ នៃសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា។ ភាគីត្រូវដាក់ចម្លើយតបមិនអោយលើសពីថ្ងៃទី ០៨ មេសា ឆ្នាំ ២០០៩ ដោយកំរិតត្រឹម ២ទំព័រជាភាសាបារាំង ឬ អង់គ្លេស និងដោយមិនអោយលើសពី ៤

ទំព័រជាភាសាខ្មែរ។

៤. នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំង និងនាំមកកាន់សាលសវនាការវិញនៅថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៩  មុនម៉ោង ៩.០០ ព្រឹក។

ដីកាសម្រាប់ការពន្យាពេលសវនាការ

- អង្គជំជម្រះសម្រេចផ្អាកសវនាការ និងបន្តនៅថ្ងៃច័ន្ទ ទី ០៧ ខែ មេសា ឆ្នាំ ២០០៩ នៅម៉ោង ៩.០០ ព្រឹក ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៩

ក្រឡាបញ្ជី ក្រឡាបញ្ជី

លឹម ស៊ុយហុង ណាគាសា